ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ
ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
(គ.ស.ហ.)
លេខៈ ០០៣ ... [illegible]

# គោលការណ៍ណែនាំ
# ស្តីពី
# ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការស៊ើបអង្កេត និងកិច្ចសហការជាតិក្នុងការស៊ើបអង្កេត

ប្រទេសកម្ពុជាជាសមាជិករបស់ក្រុមអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (Asia/Pacific Group on Money Laundering-APG)។ ប្រទេសកម្ពុជាបានអនុវត្តអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force-FATF) និងអនុវត្តកាតព្វកិច្ចនានាក្នុងនាមសមាជិក APG ដោយរួមបញ្ចូលទាំងការស៊ើបអង្កេតសំអាងនៃបទល្មើស និងបទល្មើសសម្អាតប្រាក់ ព្រមទាំងការស្វែងរកទ្រព្យពាក់ព័ន្ធនឹងបទល្មើស និងការរឹបអូសផលនិងទ្រព្យសម្បត្តិខុសច្បាប់ទាំងនោះ។

អាជ្ញាធរអនុវត្តច្បាប់របស់កម្ពុជាដែលមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ បានខិតខំបំពេញភារកិច្ចរបស់ខ្លួនតាមការកំណត់ដោយច្បាប់ ក្នុងការស៊ើបអង្កេតសំអាងនៃបទល្មើស, បទល្មើសសម្អាតប្រាក់, ការស្វែងរកទ្រព្យពាក់ព័ន្ធនឹងបទល្មើស និងការរឹបអូសផលនិងទ្រព្យសម្បត្តិខុសច្បាប់ទាំងនោះ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០២០, ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ឆ្នាំ២០២០ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ជាលទ្ធផល, សំអាងនៃបទល្មើស និងបទល្មើសសម្អាតប្រាក់ ត្រូវបានស៊ើបអង្កេត និងកសាងសំណុំរឿងបញ្ជូនទៅតុលាការជាបន្តបន្ទាប់ ហើយទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសភាគច្រើន ក៏ត្រូវបានកំណត់អត្តសញ្ញាណតាំងពីដំណាក់កាលដំបូងនៅពេលចាប់ផ្តើមស៊ើបអង្កេត ឃាត់ទុក បង្កក និងរឹបអូសផងដែរ។

ដើម្បីជួយសម្រួលដល់អាជ្ញាធរមានសមត្ថកិច្ចស៊ើបអង្កេត និងមន្ត្រីនគរបាលយុត្តិធម៌បំពេញភារកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានតាមសមត្ថកិច្ចរបស់ខ្លួន រួមទាំងការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ស្របគ្នា និងការស្វែងរកទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសនោះ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយ-ភាយអាវុធមហាប្រល័យ ដាក់ចេញនូវគោលការណ៍ណែនាំ ដូចខាងក្រោម៖

### ក-ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការស៊ើបអង្កេត

អាជ្ញាធរអនុវត្តច្បាប់ដែលមិនទាន់មាននីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការស៊ើបអង្កេត (Standard Operating Procedure-SOP) ត្រូវរៀបចំ SOP សម្រាប់អនុវត្តក្នុងស្ថាប័នរបស់ខ្លួន។ SOP នេះ គួរបញ្ចូលនូវស្តង់ដាគោលអប្បបរមាមួយចំនួន ដូចខាងក្រោម៖

១- SOP ជាការកំណត់របៀបរបបការងារឱ្យមន្ត្រីនគរបាលយុត្តិធម៌បំពេញការងាររបស់ខ្លួនលើការងារស៊ើបអង្កេតបទល្មើសក្នុងសមត្ថកិច្ចរបស់ខ្លួន និងត្រូវពិនិត្យ ស្វែងរកបទល្មើសសម្អាតប្រាក់ឈានដល់ការស៊ើបអង្កេតស្របគ្នាតាំងពីដំណាក់កាលដំបូង និងធ្វើការស៊ើបអង្កេតហិរញ្ញវត្ថុ។

២- នៅក្នុង SOP គួរកំណត់នូវអ្វីដែលក្រសួង-ស្ថាប័ន ឬអង្គភាពអាចជួយដល់មន្ត្រីនគរបាលយុត្តិធម៌របស់ខ្លួនឱ្យបំពេញភារកិច្ចក្នុងការកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ក្រសួង-ស្ថាប័ន ឬអង្គភាព អាចជួយដល់មន្ត្រីនគរបាលយុត្តិធម៌របស់ខ្លួនលើ ២ ផ្នែក រួមមាន៖

- ក្រសួង-ស្ថាប័ន ឬអង្គភាព ត្រូវប្រើយន្តការដែលខ្លួនមាន ដើម្បីជួយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។
- ក្រសួង-ស្ថាប័ន ឬអង្គភាព ត្រូវស្នើទៅក្រសួង-ស្ថាប័ន ឬអង្គភាពផ្សេង ដើម្បីជួយដល់ការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។

៣- នៅក្នុង SOP គួរកំណត់ពី លក្ខខណ្ឌវិនិច្ឆ័យនៃសំអាងនៃបទល្មើសដែលត្រូវយកមកធ្វើការស៊ើប-អង្កេតបទល្មើសសម្អាតប្រាក់, ការចាប់ផ្តើមការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងការអនុវត្តការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងដំណាក់កាលនីមួយៗ។

៤- ការរៀបចំ SOP នេះ ត្រូវពិចារណាពីលក្ខណៈ និងស្ថានភាពអនុវត្តការងារជាក់ស្តែងរបស់ក្រសួង-ស្ថាប័ន ឬអង្គភាពនីមួយៗ ដោយសារក្រសួង-ស្ថាប័ន ឬអង្គភាពនីមួយៗមានលក្ខណៈមិនដូចគ្នាទេ។

៥- ក្នុងករណីបទល្មើសមានលក្ខណៈស្មុគស្មាញ និងមានភាពចាំបាច់ អាជ្ញាធរអនុវត្តច្បាប់នីមួយៗអាចស្វែងរកកិច្ចសហការជាតិ និងអន្តរជាតិ។

### ខ-កិច្ចសហការជាតិក្នុងការស៊ើបអង្កេត

ការស្វែងរកព័ត៌មាន និងភស្តុតាងពិតជាមានសារៈសំខាន់សម្រាប់ការស៊ើបអង្កេត និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន បានអនុញ្ញាតឱ្យស្ថាប័នតុលាការ និងក្រសួង-ស្ថាប័នមួយចំនួនទទួលបានសិទ្ធិពិសេសក្នុងការទទួលបានព័ត៌មានដែលមានលក្ខណៈចាំបាច់។ ដូចនេះ, ក្រសួង-ស្ថាប័នផ្សេងៗទៀត ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ គួរស្នើសុំព័ត៌មានទាំងនោះតាមមធ្យោបាយ ដូចខាងក្រោម៖

១- **ការស្នើសុំ CDR (Call Data Record)**៖ ច្បាប់បានអនុញ្ញាតឱ្យតុលាការ នគរបាលជាតិ កង-រាជអាវុធហត្ថ និងអង្គភាពប្រឆាំងអំពើពុករលួយ អាចស្នើសុំ CDR បាន ចំណែកក្រសួង-ស្ថាប័ន

ផ្សេងទៀតប្រសិនបើចង់បាន CDR បម្រើដល់ការស៊ើបអង្កេតរបស់ខ្លួន អាចស្នើសុំទៅតុលាការ នគរបាលជាតិ កងរាជអាវុធហត្ថ ឬអង្គភាពប្រឆាំងអំពើពុករលួយឱ្យជួយបាន។

២- **ការស្នើសុំអត្តសញ្ញាណយានយន្ត៖** ក្រសួង-ស្ថាប័ន ឬអង្គភាព ដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដែលចង់បានអត្តសញ្ញាណយានយន្ត ដើម្បីបម្រើដល់ការស៊ើបអង្កេតរបស់ខ្លួន អាចស្នើសុំទៅ៖

- **ក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត៖** ចំពោះយានយន្តដែលមានស្លាកលេខទូទៅ និងស្លាកលេខរដ្ឋ ដោយយោងតាមឧត្តមានុវត្តផ្នែករដ្ឋបាល ដើម្បីធានាបានភាពឆាប់រហ័ស ឬការសម្ងាត់នៃការស៊ើបអង្កេត ឬតាមយន្តការណាមួយដែលមានការឯកភាពគ្នាជាប្រក្រតីចេញចូលរវាងស្ថាប័ន និងស្ថាប័នលើការងារប្រឆាំងការសម្អាតប្រាក់
- **ក្រសួងមហាផ្ទៃ៖** ចំពោះយានយន្តដែលមានស្លាកលេខនគរបាល
- **ក្រសួងការពារជាតិ៖** ចំពោះយានយន្តដែលមានស្លាកលេខខេមរភូមិន្ទ

៣- **ការស្នើសុំព័ត៌មាន ឬប្រវត្តិធ្វើដំណើរឆ្លងប្រទេស៖** ក្រសួង-ស្ថាប័ន ឬអង្គភាពដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដែលចង់បានព័ត៌មាន ឬប្រវត្តិធ្វើដំណើររបស់បុគ្គលពាក់ព័ន្ធ ដើម្បីបម្រើដល់ការស៊ើបអង្កេតរបស់ខ្លួន អាចស្នើសុំទៅ**ក្រសួងមហាផ្ទៃ** ឬអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដោយយោងតាមឧត្តមានុវត្តផ្នែករដ្ឋបាល ដើម្បីធានាបានភាពឆាប់រហ័ស ឬការសម្ងាត់នៃការស៊ើបអង្កេត ឬតាមយន្តការណាមួយដែលមានការឯកភាពគ្នាជាប្រក្រតីចេញចូលរវាងស្ថាប័ន និងស្ថាប័នលើការងារប្រឆាំងការសម្អាតប្រាក់។

៤- **ការស្នើសុំអត្តសញ្ញាណបុគ្គល សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ៖** ក្រសួង-ស្ថាប័ន ឬអង្គភាពដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដែលចង់បានអត្តសញ្ញាណរបស់បុគ្គលពាក់ព័ន្ធ ដើម្បីបម្រើដល់ការស៊ើបអង្កេតរបស់ខ្លួន អាចស្នើសុំទៅ**ក្រសួងមហាផ្ទៃ** ឬអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ឬស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដោយយោងតាមឧត្តមានុវត្តផ្នែករដ្ឋបាល ដើម្បីធានាបានភាពឆាប់រហ័ស ឬការសម្ងាត់នៃការស៊ើបអង្កេត ឬតាមយន្តការណាមួយដែលមានការឯកភាពគ្នាជាប្រក្រតីចេញចូលរវាងស្ថាប័ន និងស្ថាប័នលើការងារប្រឆាំងការសម្អាតប្រាក់។

៥- **ការស្នើសុំព័ត៌មានអចលនទ្រព្យ៖** ក្រសួង-ស្ថាប័ន ឬអង្គភាពដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដែលចង់បានព័ត៌មានពីអចលនទ្រព្យ ដើម្បីបម្រើដល់ការស៊ើបអង្កេតរបស់ខ្លួន អាចស្នើសុំទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ដោយយោងតាមឧត្តមានុវត្តផ្នែករដ្ឋបាល ដើម្បីធានាបានភាពឆាប់រហ័ស ឬការសម្ងាត់នៃការស៊ើបអង្កេត ឬតាមយន្តការណាមួយដែលមានការឯកភាពគ្នាជាប្រក្រតីចេញចូលរវាងស្ថាប័ន និងស្ថាប័នលើការងារប្រឆាំងការសម្អាតប្រាក់។

៦- **ការស្នើសុំព័ត៌មានរបស់ក្រុមហ៊ុន៖** ក្រសួង-ស្ថាប័ន ឬអង្គភាពដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដែលចង់បានព័ត៌មានរបស់ក្រុមហ៊ុន ដើម្បីបម្រើដល់ការស៊ើបអង្កេតរបស់ខ្លួន អាចស្នើសុំទៅក្រសួងពាណិជ្ជកម្ម។

៧- **ការស្នើសុំព័ត៌មានពីក្រសួង-ស្ថាប័ន ឬអង្គភាពសាធារណៈផ្សេងៗទៀត៖** ក្រសួង-ស្ថាប័ន ឬអង្គភាពដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដែលចង់បានព័ត៌មានផ្សេងទៀត ដើម្បីបម្រើដល់ការស៊ើបអង្កេតរបស់ខ្លួន អាចស្នើសុំទៅក្រសួង-ស្ថាប័ន ឬអង្គភាពសាធារណៈផ្សេងៗទៀតដែលពាក់ព័ន្ធ។

## គ-ការស្នើសុំព័ត៌មានហិរញ្ញវត្ថុទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ដើម្បីមានមូលដ្ឋានក្នុងការកសាងសំណុំរឿងបទល្មើសសម្អាតប្រាក់, ការស្រាវជ្រាវប្រមូលព័ត៌មានហិរញ្ញវត្ថុពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ពិតជាមានសារសំខាន់ក្នុងការកំណត់គន្លងប្រាក់ ឬផ្តល់មូលដ្ឋានបន្ថែមទៀតបម្រើដល់ការស៊ើបអង្កេត និងការសាងសំណុំរឿង។ ដូចនេះ, ក្រសួង-ស្ថាប័ន ឬអង្គភាពដែលទទួលបន្ទុក ត្រូវយកចិត្តទុកដាក់លើចំណុច ដូចខាងក្រោម៖

១- ក្រសួង-ស្ថាប័ន ឬអង្គភាពដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ អាចស្នើសុំរបាយការណ៍ព័ត៌មានហិរញ្ញវត្ថុទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដោយអនុវត្តស្របតាមច្បាប់ជាធរមាននៅក្នុងវិស័យដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និង/ឬ ដោយមានកិច្ចសហការពីស្ថាប័នតុលាការ តាមការចាំបាច់។

២- ក្រោយពីទទួលបានរបាយការណ៍ឆ្លើយតបមកវិញ លើសំណើសុំព័ត៌ហិរញ្ញវត្ថុពីអង្គភាពស៊ើប-ការណ៍ហិរញ្ញវត្ថុកម្ពុជា, ក្រសួង-ស្ថាប័ន ឬអង្គភាពដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការសិក្សា វិភាគ និងចាត់នីតិវិធីបន្ត ដែលមានកំណត់នៅក្នុង SOP របស់ក្រសួង-ស្ថាប័ន ឬអង្គភាពរៀងៗខ្លួន ដើម្បីស្វែងរកអត្តសញ្ញាណបុគ្គលនិងភស្តុតាងពាក់ព័ន្ធ និងកសាងសំណុំ-រឿងបញ្ជូនទៅតុលាការ ព្រមទាំងស្នើសុំឱ្យមានការបង្កកទ្រព្យសម្បត្តិដែលសង្ស័យថាមានជាប់ពាក់ព័ន្ធនឹងការសម្អាតប្រាក់ ឱ្យបានទាន់ពេលវេលា និងឆាប់រហ័ស។

៣- ករណីក្រសួង-ស្ថាប័ន ឬអង្គភាព បានព័ត៌មានជារបាយការណ៍ស៊ើបការណ៍ហិរញ្ញដែលបញ្ជូនដោយឯកឯង ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា, ក្រសួង-ស្ថាប័ន ឬអង្គភាពនោះ ត្រូវធ្វើការសិក្សា វិភាគ និងចាត់នីតិវិធីបន្ត ដែលមានកំណត់នៅក្នុង នីតិវិធីប្រតិបត្តិតាម ក្រសួង-ស្ថាប័ន ឬអង្គភាពរៀងៗខ្លួន ដើម្បីស្វែងរកអត្តសញ្ញាណបុគ្គល និងភស្តុតាងពាក់ព័ន្ធ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។

៤- ក្រោយពីអនុវត្តការស៊ើបអង្កេតដោយគោរពតាមបច្ចេកទេសដូចមានកំណត់ក្នុង SOP ប៉ុន្តែការស៊ើបអង្កេតនៅតែមិនអាចបានលទ្ធផល និងឈានដល់ការកសាងសំណុំរឿងសម្អាតប្រាក់, ក្រសួង-ស្ថាប័ន ឬអង្គភាពដែលទទួលបន្ទុក ត្រូវមានបញ្ជីស្ថិតិ និងបន្តធ្វើបច្ចុប្បន្នភាពលើស្ថិតិនៃការស៊ើបអង្កេតទាំងនោះជាប្រចាំ ហើយគួររៀបចំជាករណីសិក្សាទាំងការស៊ើបអង្កេតដែល

អាចឈានដល់ការកសាងសំណុំរឿងសម្អាតប្រាក់ ទាំងការស៊ើបអង្កេតដែលមិនអាចឈានដល់ការកសាងសំណុំរឿងសម្អាតប្រាក់។

៥- គ្រប់ករណីដែលបានស៊ើបអង្កេតទាំងអស់ ទោះជាបានទទួលលទ្ធផល ឬមិនបានលទ្ធផលដែលអាចឈានដល់ការចោទប្រកាន់បទល្មើសសម្អាតប្រាក់, ក្រសួង-ស្ថាប័ន ឬអង្គភាពដែលទទួលបន្ទុក ត្រូវបន្តចាត់ការតាមនីតិវិធីច្បាប់ជាធរមាន។

ដើម្បីបម្រើដល់ប្រសិទ្ធភាពនៃការស៊ើបអង្កេត រួមទាំងការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការ ក្រសួង-ស្ថាប័ន ឬអង្គភាពដែលទទួលបានសំណើដូចបានរៀបរាប់ខាងលើ ត្រូវឆ្លើយតបតាមសំណើជាបន្ទាន់។

ក្រសួង-ស្ថាប័ន ឬអង្គភាពដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ ត្រូវមានទំនាក់ទំនងទ្វេភាគី ដើម្បីជួយគ្នាទៅវិញទៅមក។

ទទួលបានគោលការណ៍ណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន អនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារ ព្រមទាំងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ត្រូវសហការអនុវត្តគោលការណ៍ណែនាំនេះឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១២ កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០២២
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និងជាប្រធាន គ.ស.ហ.

សម្តេចក្រឡាហោម ស ខេង

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ